ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៧០៤ ព.ណ. បណ.ប្រក

# ប្រកាស
## ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់
## នាយកដ្ឋានអភិវឌ្ឍន៍វិស័យឯកជន

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ១៣១ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

### សម្រេច

**ប្រការ ១ :**

នាយកដ្ឋានអភិវឌ្ឍន៍វិស័យឯកជនស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំផ្ទាល់របស់អគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស មានមុខងារ និងភារកិច្ចដូចតទៅ៖

- កំណត់សន្ទិធិទំនិញយុទ្ធសាស្ត្រ និងអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលដើម្បីអភិវឌ្ឍន៍វិស័យឯកជន
- តាមដានថ្លៃទំនិញ និងដំណើរការទីផ្សារ
- គ្រប់គ្រងប្រព័ន្ធព័ត៌មានទីផ្សារ
- ធ្វើជាអាណាព្យាបាល បច្ចេកទេសសភាពាណិជ្ជកម្ម និងសមាគមពាណិជ្ជកម្ម
- ជួយចាត់ចែងកិច្ចសម្រួលពាណិជ្ជកម្ម



ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ:(៨៥៥)-២៣ ៨៦៦ ៤៦៩
Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA
Phone/Facsimile: (855)-23 866 469

- គ្រប់គ្រងទីផ្សារ និងអនុវត្តគោលនយោបាយពាណិជ្ជកម្មក្នុងស្រុក ដូចជាបិទស្លាកថ្លៃ ទំនិញ ត្រួតពិនិត្យស្តុកទំនិញយុទ្ធសាស្ត្រ និងទំនិញចាំបាច់តាមការកំណត់របស់រាជរដ្ឋាភិបាល
- សហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីជំរុញចលនាភូមិ១ផលិតផល១
- កសាងផែនការតម្រូវការសម្រាប់ទទួលការបណ្តុះបណ្តាលលើមុខជំនាញពាក់ព័ន្ធនឹងការងារអាជីវកម្ម ពាណិជ្ជកម្ម ដើម្បីពង្រឹងសមត្ថភាពមន្ត្រី និងផ្នែកឯកជនទាំងរយៈពេលខ្លី មធ្យម និងរយៈពេលវែង តាមការចាំបាច់
- រៀបចំការស្រាវជ្រាវ វិភាគ ឃ្លាំមើលទីផ្សារ និងលំហូរផលិតផលកម្ពុជា
- ចូលរួមសហការជាមួយនាយកដ្ឋានអភិវឌ្ឍន៍ទីផ្សារក្នុងការសិក្សាស្រាវជ្រាវផលិតផល និងទីផ្សារសក្តានុពលនៅក្នុង និងក្រៅប្រទេសរួមទាំងការចូលរួមនៅក្នុងដំណើរបេសកកម្មផ្សព្វផ្សាយពាណិជ្ជកម្មនានា
- បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ប្រការ ២ :**

នាយកដ្ឋានអភិវឌ្ឍន៍វិស័យឯកជន ដឹកនាំដោយ ប្រធាននាយកដ្ឋានមួយរូប និងអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការ។

**ប្រការ ៣ :**

នាយកដ្ឋានអភិវឌ្ឍន៍វិស័យឯកជន មានការិយាល័យចំណុះចំនួន ០៤ គឺៈ

១- ការិយាល័យរដ្ឋបាល និងផែនការ

២- ការិយាល័យពិនិត្យឃ្លាំមើលសកម្មភាពពាណិជ្ជកម្ម

៣- ការិយាល័យអភិវឌ្ឍន៍ស្ថាប័នពាណិជ្ជកម្ម

៤- ការិយាល័យអភិវឌ្ឍន៍ផលិតផល

**ប្រការ ៤ :**

ការិយាល័យរដ្ឋបាល និងផែនការ មានភារកិច្ច ៖

- រៀបចំ និងគ្រប់គ្រងថវិកាព្រមទាំងលើកផែនការចំណាយ និងផែនការសកម្មភាពសម្រាប់នាយកដ្ឋាន
- លើកសំណើ និងគ្រប់គ្រងការប្រើប្រាស់សម្ភារៈការិយាល័យ
- គ្រប់គ្រងទ្រព្យសម្បត្តិ ឧបករណ៍សម្ភារៈ និងមធ្យោបាយធ្វើដំណើរនានាដែលជាសម្បត្តិរបស់នាយកដ្ឋាន
- រៀបចំគម្រោងតម្រូវការចាំបាច់ សម្រាប់ការបណ្តុះបណ្តាលធនធានមនុស្សរបស់នាយកដ្ឋាន និងវិស័យឯកជន ដោយសហការជាមួយនឹងវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវ
- គ្រប់គ្រងវត្តមាន និងបេសកកម្មរបស់បុគ្គលិកមន្ត្រីរាជការនៃនាយកដ្ឋាន
- រៀបចំសំណើតម្លើងឋានន្តរស័ក្តិ កាំប្រាក់បៀវត្ស ប្រាក់បំណាច់មុខងារ គ្រឿង

ឥស្សរិយយស ព្រមទាំងគ្រប់គ្រងព័ត៌មានមន្ត្រីរាជការក្នុងនាយកដ្ឋាន

- បំពេញការងាររដ្ឋបាល និងរៀបចំរបាយការណ៍បូកសរុបប្រចាំខែ ត្រីមាស ឆមាស និងរបាយការណ៍ប្រចាំឆ្នាំរបស់នាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ប្រការ ៥ :**

ការិយាល័យពិនិត្យឃ្លាំមើលសកម្មភាពពាណិជ្ជកម្ម មានភារកិច្ច ៖

- គ្រប់គ្រងសន្និធិទំនិញយុទ្ធសាស្ត្រ និងទំនិញចាំបាច់
- តាមដានថ្លៃទំនិញ និងស្ថេរភាពទីផ្សារ តាមរយៈការពិនិត្យឃ្លាំមើលសកម្មភាពអាជីវកម្ម និងការផ្តល់ព័ត៌មានទាន់ពេលវេលាសម្រាប់វិស័យឯកជនដោយសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ
- គ្រប់គ្រងប្រព័ន្ធព័ត៌មានទីផ្សារ
- ត្រួតពិនិត្យការអនុវត្ត និងចេញលិខិតអនុញ្ញាតបិទស្លាកថ្លៃលើមុខទំនិញជារូបិយប័ណ្ណបរទេស និងលើកទឹកចិត្តការបិទស្លាកថ្លៃទំនិញជាប្រាក់រៀលតាមទីផ្សារ
- ជួយចាត់ចែងកិច្ចសម្រួលពាណិជ្ជកម្ម សម្រាប់វិស័យឯកជន ដោយសហការជាមួយស្ថាប័ននានា
- ត្រួតពិនិត្យតាមដានការអនុវត្តការងារពាណិជ្ជកម្ម នៅច្រកចេញ ចូលតែមួយនៅតាមរាជធានី ខេត្ត និងការធ្វើប្រតិភូកម្មផ្សេងៗ
- ផ្តល់ពត៌មានអំពីច្បាប់បទបញ្ញត្តិទាំងឡាយណា ដែលមានផលប៉ះពាល់ដល់សកម្មភាពអាជីវកម្ម ជូនដល់វិស័យឯកជន
- បំពេញភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ប្រការ ៦ :**

ការិយាល័យអភិវឌ្ឍន៍ស្ថាប័នពាណិជ្ជកម្ម មានភារកិច្ច ៖

- ជួយអភិវឌ្ឍន៍ និងពង្រឹងសភាពាណិជ្ជកម្ម:
  - ណែនាំ និងពង្រឹងការងារបច្ចេកទេសដល់សភាពាណិជ្ជកម្មសម្រាប់ការគ្រប់គ្រង និងដំណើរការសភាពាណិជ្ជកម្ម
  - តាមដានពិនិត្យស្ថានភាពរបស់សភាពាណិជ្ជកម្មទូទាំងរាជធានី ខេត្ត រួមទាំងការបង្កើតសភាពាណិជ្ជកម្មថ្មី និងការបោះឆ្នោតអាណត្តិថ្មី
  - ជួយសម្របសម្រួល រៀបចំមហាសន្និបាតសភាពាណិជ្ជកម្មទូទាំងរាជធានី ខេត្ត និងជំរុញកិច្ចសហប្រតិបត្តិការសភាពាណិជ្ជកម្មថ្នាក់ជាតិ និងអន្តរជាតិ

- ផ្សព្វផ្សាយពីសារប្រយោជន៍នៃការរៀបចំសភាពាណិជ្ជកម្ម និងរៀបចំច្បាប់ និងបទបញ្ញត្តិទាំងឡាយណាដែលទាក់ទងនឹងការបង្កើតនិងការប្រព្រឹត្តទៅនៃសភាពាណិជ្ជកម្ម ។

– សហការ និងពង្រឹងមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត:

- ពង្រឹងការអភិវឌ្ឍន៍មន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ

– ជួយអភិវឌ្ឍន៍ និងពង្រឹងសមាគមអាជីវកម្ម ពាណិជ្ជកម្ម:

- ផ្សព្វផ្សាយពីសារៈប្រយោជន៍នៃការរៀបចំសមាគមអាជីវកម្ម ពាណិជ្ជកម្ម និងរៀបចំច្បាប់ និងបទបញ្ញត្តិទាំងឡាយណាដែលទាក់ទងនឹងការបង្កើតសមាគម
- តាមដាន និងពិនិត្យស្ថានភាពរបស់សមាគមអាជីវកម្ម ពាណិជ្ជកម្មទូទាំងរាជធានី ខេត្ត រួមទាំងការជួយបង្កើតសមាគមអាជីវកម្ម ពាណិជ្ជកម្ម និងជំរុញសកម្មភាពសម្រាប់ការប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពរបស់សមាគមទាំងនោះ
- ចេញវិញ្ញាបនប័ត្រទទួលស្គាល់និងតំកល់ទុកលក្ខន្តិកៈសមាគមអាជីវកម្ម ពាណិជ្ជកម្ម ព្រមទាំងផ្សព្វផ្សាយអំពីនីតិវិធី និងបែបបទនៃការធ្វើអាជីវកម្មនានាសម្រាប់ការអភិវឌ្ឍន៍សមាគម និងអាជីវកម្មខ្នាតតូច និងមធ្យម នៅកម្ពុជា

– បំពេញភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ប្រការ ៧ :**

ការិយាល័យអភិវឌ្ឍន៍ផលិតផល មានភារកិច្ចៈ

– សហការជាមួយដៃគូពាក់ព័ន្ធដើម្បីជំរុញ ចលនាភូមិ១ ផលិតផល១ និងចុះផ្សព្វផ្សាយតាមរយៈសិក្ខាសាលា និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗទៀត

– សហការសិក្សា និងអភិវឌ្ឍន៍ខ្សែសង្វាក់ប្រព័ន្ធផ្គត់ផ្គង់ និងខ្សែសង្វាក់ប្រព័ន្ធតម្លៃផលិតផល

– ជំរុញការធ្វើពិពិធកម្មការធ្វើអាជីវកម្ម ពិសេសការនាំចេញផលិតផលដែលមានសក្តានុពលនៅកម្ពុជា

– សហការអភិវឌ្ឍន៍ផលិតផលសូត្រខ្មែរ និងជំរុញការអភិវឌ្ឍន៍ផលិតផលទំនិញម៉ាកសម្គាល់ភូមិសាស្ត្រ

– លើកទឹកចិត្ត ជួយសម្របសម្រួល និងពិនិត្យតាមដានការអនុវត្ត កិច្ចសន្យាដាំដុះផលិតផលកសិកម្ម

- ស្រាវជ្រាវ និងកំណត់ផលិតផលសក្តានុពលថ្មីៗទៀត ដែលអាចធ្វើអាជីវកម្មបាន ជាពិសេសផលិតផលសម្រាប់ធ្វើការនាំចេញ ដោយសហការជាមួយ អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម
- ជួយផ្តល់ព័ត៌មាន និងសហការណែនាំអំពីការអភិវឌ្ឍន៍គុណភាពផលិតផលរួមទាំងការកែលំអស្រោមសំបកវេចខ្ចប់ អនាម័យ និងភូតគាមអនាម័យ ព្រមទាំងលក្ខខ័ណ្ឌទីផ្សារផ្សេងៗ រួមទាំងរបាំងមិនមែនពន្ធនានា
- បំពេញភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ប្រការ ៨ :**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានអង្គភាពចំណុះក្រសួង និងប្រធានមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ[illegible] ឆ្នាំ២០១៤

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ស៊ុន ចាន់ថុល**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ៨
- ឯកសារ-កាលប្បវត្តិ

# អង្គការលេខរបស់នាយកដ្ឋានអភិវឌ្ឍន៍វិស័យឯកជន

